**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងរវាងនាយិកាក្រុមហ៊ុនចាន់រីទ្រីនិងតំណាងកម្មករនិយោជិក
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ ២០២២ វេលាម៉ោង ៩ និង ៣០នាទី នៅក្នុងក្រុមហ៊ុនភោជនីយដ្ឋានចាន់រីទ្រីមានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិក។

នៅក្នុងអង្គប្រជុំនេះនាយិកាក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុនថា ដោយសារការរីករាលដាលនិងចម្លងនៃជំងឺរលាកសួតប្រភេទថ្មីCovid-19ដែលជាហេតុបណ្តាលអោយមានផលប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកហើយក៏ជាហេតុដែលធ្វើអោយក្រុមហ៊ុនទទួលរងការខាតបង់ មិនមានប្រាក់ចំណូលសំរាប់ទ្រទ្រង់ប្រតិបត្តិការណ៍បន្តទៀតបាន។

ហេតុដូចនេះក្រុមហ៊ុនបានសំរេចចិត្តធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិកទាំងអស់ ចំនួន៣៣នាក់(ស្រី១១នាក់)រយៈពេល៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ រហូតដល់ទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ នៅក្នុងកំឡុងពេលនៃការព្យួរនេះកម្មករនិយោជិកនឹងមិនទទួលបានអត្ថប្រយោជន៍អ្វីពីក្រុមហ៊ុនឡើយ។ អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១០និង៣០នាទីនាថ្ងៃខែឆ្នាំដដែល ដោយសារភាគីទាំងសងខាងមានការស្និទ្ធស្នាលនិងយោគយល់គ្នាក្រោមស្មារតីទទួលនិងសហការគ្នាយ៉ាងរលូន។

ថ្ងៃព្រហស្បត៍១៣កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័កព.ស២៥៦៦
សៀមរាប ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២

ហត្ថលេខា និងត្រា នាយិកា

តំណាងកម្មករនិយោជិក